**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ១២១/២៤ ក.ប/ខ.ល

# សារលិខិតថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**

**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ**

**ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**

***ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងឱកាសអភិលក្ខិតកាលដ៏មហាសិរីមង្គលថ្លៃថ្លាប្រកបដោយសេចក្តីសោមនស្សរីករាយ នៃ**ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ខួបលើកទី១១៣** ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមព្រះបរមរាជានុញ្ញាតថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** នូវព្រះសព្ទសាធុការពរជ័យ សិរីវឌ្ឍនា មហាប្រសើរគ្រប់ប្រការ ប្រកបដោយកតញ្ញូតាធម៌ និងកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះរាជបញ្ញាញាណឈ្វេងយល់ និងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមថ្លៃថ្លាប្រកបដោយទសពិធរាជធម៌ ចំពោះជាតិ មាតុភូមិ ប្រជានុរាស្ត្រ និងកិច្ចការបរទេសរបស់ព្រះអង្គ បន្ថែមពីនេះព្រះអង្គតែងមានទឹកព្រះទ័យជ្រះថ្លាបរិសុទ្ធ ប្រោសព្រះរាជទានព្រះរាជទ្រព្យយ៉ាងច្រើនជួយដល់វិស័យព្រះពុទ្ធសាសនា អប់រំ សង្គមកិច្ច សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេស ការជំរុញ និងលើកកម្ពស់ តួនាទី និងតម្លៃស្ត្រីកម្ពុជាឱ្យមានសក្តានុពលកាន់តែខ្លាំងក្លា ព្រមទាំងមានការទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះ ទូលព្រះបង្គំទាំងអស់គ្នា សូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ វត្ថុស័ក្តិសិទ្ធិក្នុងលោក បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ និងដួងព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ សូមជួយបីបាច់ថែរក្សា **សម្តេចព្រះមហាក្សត្រី** សូមទ្រង់មានព្រះបញ្ញាញាណឈ្លាសវៃ ព្រះកាយពលមាំមួន ព្រះរាជសុខភាពល្អបរិបូរណ៍ និងព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់ប្រថាប់ជាម្លប់ត្រជាក់ត្រជុំ សុខដុមរមនា នៃព្រះជារាស្ត្រខ្មែរគ្រប់រូប និងសូមសមប្រកបដោយព្រះពុទ្ធពរដ៏ប្រសើរថ្លៃថ្លាទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ប្រោសព្រះរាជទានមេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ៦រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩